**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មាន
# ស្តីពី
# ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្រាប់ក្រុមអាយុ ៦០ឆ្នាំឡើង ចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នារសៀលថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១ ក្រសួងសុខាភិបាល សូមគោរពជម្រាបជូន និងធ្វើការណែនាំជូនដល់សាធារណជនទាំងអស់ឲ្យបានជ្រាបពីនីតិវិធីនៃការចាក់វ៉ាក់សាំងកូវីដ-១៩នេះ មានដូចខាងក្រោម៖

១. ដោយសង្កេតឃើញថា បងប្អូនប្រជាពលរដ្ឋដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង មានបំណងស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩ ច្រើន ហើយសម្រុកមកចាក់ដោយមានការកកស្ទះ និងរង់ចាំយូរនោះ ក្រសួងសុខាភិបាល សូមធ្វើការផ្អាកការចាក់វ៉ាក់សាំង AstraZeneca ជាបណ្តោះអាសន្នសិននៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ហើយនឹងចាប់ដំណើរការចាក់ឡើងវិញនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ដើម្បីទុកពេលវេលាជូនអាជ្ញាធរថ្នាក់ក្រោមជាតិនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ធ្វើការសម្របសម្រួលរៀបចំក្រុមប្រជាជនដែលនៅក្នុងក្រុមអាយុនេះ ដើម្បីមកចាក់ទៅតាមថ្ងៃនីមួយៗវិញ។ រីឯ វ៉ាក់សាំងស៊ីណូហ្វាម សម្រាប់ក្រុមអាទិភាពដែលក្រសួងធ្លាប់បានចេញសេចក្តីជូនព័ត៌មានរួចហើយនោះ នៅតែបន្តចាក់ដដែល ដោយមិនមានការផ្អាកនោះឡើយ។

២. ការចាក់វ៉ាក់សាំងកូវីដ-១៩ គឺដោយឈរលើ **គោលការណ៍ស្ម័គ្រចិត្ត និងមិនគិតថ្លៃ**។

៣. វ៉ាក់សាំងដែលផលិតនៅប្រទេសឥណ្ឌាដោយមានអាជ្ញាប័ណ្ណពី AstraZeneca "**កូវីសេល** (COVISHIELD)" ចាក់លើកទី១ (ដូសទី១) រួចហើយ សូមអញ្ជើញមកទទួលការចាក់វ៉ាក់សាំងដដែលនេះជាលើកទី២ (ដូសទី២) ក្នុងរយៈពេលពី ៤ ទៅ ៨សប្តាហ៍ បន្ទាប់ពីថ្ងៃចាក់លើកទី១ កុំបីអាក់ខានឡើយ ហើយនឹងចាក់ជូនចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ជូនដល់ប្រជាពលរដ្ឋ ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ ដែលរៀបចំដោយអាជ្ញាធរមូលដ្ឋាន។

៤. ការចាក់វ៉ាក់សាំង នឹងប្រព្រឹត្តទៅ ដូចខាងក្រោមនេះ៖

៤.១. ចំពោះការចាក់វ៉ាក់សាំង AstraZeneca បន្តឡើងវិញនេះ អាជ្ញាធរមូលដ្ឋាន (ភូមិ/ឃុំ-សង្កាត់) នៃរាជធានី-ខេត្ត នឹងចុះស្រង់ស្ថិតិ រួចជូនលិខិតអញ្ជើញដល់បងប្អូនប្រជាពលរដ្ឋ ឲ្យទៅទទួលវ៉ាក់សាំងរៀងរាល់ម៉ោងធ្វើការ នៅតាមមន្ទីរពេទ្យបង្អែករាជធានី-ខេត្ត និងមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ ដែលស្ថិតនៅក្នុងមូលដ្ឋានរបស់បងប្អូនប្រជាពលរដ្ឋកំពុងរស់នៅ៖

- ចំពោះយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ (AstraZeneca /Serum Institute of India "COVISHIELDTM") នឹងត្រូវផ្តល់ជូនក្រុមមនុស្សដែលងាយរងគ្រោះនឹងជំងឺកូវីដ-១៩ ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ ក្នុងមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ តែប៉ុណ្ណោះ។ ដើម្បីទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ បងប្អូនប្រជាពលរដ្ឋ ត្រូវភ្ជាប់មកជាមួយនូវលិខិតអញ្ជើញដែលទទួលបានពីអាជ្ញាធរមូលដ្ឋាន ព្រមទាំងត្រូវបង្ហាញឯកសារសម្គាល់អត្តសញ្ញាណ ដូចជា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សំបុត្រអត្រានុកូលដ្ឋាន និងលិខិតឆ្លងដែន ជាដើម ដើម្បីផ្ទៀងផ្ទាត់។
- ចំពោះវ៉ាក់សាំងស៊ីណូហ្វាម "Sinopharm Beijing Institute of Biological Products" ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន នឹងត្រូវផ្តល់ជូនប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ ដល់ ៥៩ឆ្នាំ ហើយត្រូវបានកំណត់ផ្តល់ជូនក្រុមមនុស្សអាទិភាព ដែលក្រសួងធ្លាប់បានចេញសេចក្តីជូនព័ត៌មានពីមុនរួចមក ដូចជា បុគ្គលិកសុខាភិបាល កងកម្លាំងនគរបាលជាតិ ចំណុះស្នងការដ្ឋានរាជធានី-ខេត្ត មន្ត្រីរាជការស៊ីវិលជួរមុខ និងមន្ត្រីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អាជ្ញាធរមូលដ្ឋាន កម្មករ-កម្មការិនីប្រមូលសំរាម។ល។ ដើម្បីទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ ក្រុមមនុស្សអាទិភាពខាងលើ ត្រូវភ្ជាប់មកជាមួយនូវលិខិតអញ្ជើញដែលទទួលបានពីអាជ្ញាធរមូលដ្ឋាន ឬ ក្រសួង-ស្ថាប័នសាមី ព្រមទាំងត្រូវបង្ហាញឯកសារសម្គាល់

អត្តសញ្ញាណ ដូចជា បណ្ណមន្ត្រីរាជការ-កងកម្លាំង អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សំបុត្រអត្រានុកូលដ្ឋាន និងលិខិតឆ្លងដែន ជាដើម ដើម្បីផ្ទៀងផ្ទាត់។

៤.២. សម្រាប់មន្ត្រីការទូត មន្ត្រីអង្គការសហប្រជាជាតិ តំណាងហិរញ្ញវត្ថុអន្តរជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ស្នើសុំឱ្យមានការរៀបចំជាក្រុមៗ និងមានបញ្ជីឈ្មោះត្រឹមត្រូវ ដែលសម្របសម្រួលដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

៤.៣. មន្ទីរពេទ្យកាល់ម៉ែត គឺជាទីកន្លែងដែលអនុញ្ញាតឱ្យចាក់សម្រាប់ឥស្សរជនជាន់ខ្ពស់ដែលមានតួនាទីចាប់ពីថ្នាក់រដ្ឋលេខាធិការឡើងទៅ និងមន្ត្រីការទូត មន្ត្រីអង្គការសហប្រជាជាតិ តំណាងហិរញ្ញវត្ថុអន្តរជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ។ ទីតាំងមូលដ្ឋានសុខាភិបាលសាធារណៈ ដែលមានចាក់វ៉ាក់សាំងកូវីដ-១៩ មានក្នុងតារាងខាងក្រោមនេះ៖

| ល.រ | ឈ្មោះរាជធានី/ខេត្ត | ទីតាំងដែលមានចាក់វ៉ាក់សាំងកូវីដ-១៩ |
|---|---|---|
| ១. | នៅថ្នាក់ជាតិ | ១. មន្ទីរពេទ្យកាល់ម៉ែត ២. មន្ទីរពេទ្យព្រះអង្គឌួង ៣. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត<br>៤. មន្ទីរពេទ្យកុមារជាតិ ៥. មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ |
| ២. | រាជធានីភ្នំពេញ | ១. មន្ទីរពេទ្យរាជធានីភ្នំពេញ ២. មន្ទីរពេទ្យបង្អែកព្រែកព្នៅ ៣. មន្ទីរពេទ្យបង្អែកច្បារអំពៅ<br>៤. មន្ទីរពេទ្យបង្អែកដង្កោ ៥. មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិន សែនសុខ ៦. មន្ទីរពេទ្យបង្អែកចតុមុខ<br>៧. មន្ទីរពេទ្យបង្អែកសម្ដេចឪ សម្ដេចម៉ែ ៨. មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង |
| ៣. | ខេត្តកណ្ដាល | ១. មន្ទីរពេទ្យជ័យជំនះ ២. មន្ទីរពេទ្យបង្អែកខ្សាច់កណ្ដាល ៣. មន្ទីរពេទ្យបង្អែកស្អាង<br>៤. មន្ទីរពេទ្យបង្អែកពញាឮ ៥. មន្ទីរពេទ្យបង្អែកលើកដែក ៦.មន្ទីរពេទ្យបង្អែកកោះធំ<br>៧. មន្ទីរពេទ្យបង្អែកប៊ុនរ៉ានី ហ៊ុនសែន ការកោង ៨. មន្ទីរពេទ្យបង្អែកអង្គស្នួល ៩. មន្ទីរពេទ្យបង្អែកកៀនស្វាយ<br>១០. មន្ទីរពេទ្យបង្អែកល្វាឯម ១១. មន្ទីរពេទ្យបង្អែកកណ្ដាលស្ទឹង |
| ៤. | ខេត្តព្រះសីហនុ | -មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ |

**សម្គាល់៖**

១. ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់ក្រុមមនុស្សខាងលើ ត្រូវបន្តធ្វើនៅរាល់ថ្ងៃធ្វើការ ចាប់ពីម៉ោង ៨:០០នាទី ព្រឹក ដល់ម៉ោង ១៧:០០នាទី ល្ងាច (ដោយសម្រាកពិសារអាហារថ្ងៃត្រង់ពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៤:០០ នាទី)។

២. ក្រសួង ក៏សូមក្រើនរំលឹកដល់អ្នកដែលបានចាក់វ៉ាក់សាំងស៊ីណូហ្វាម លើកទី១ (ដូសទី១) រួចហើយ សូមអញ្ជើញមកទទួលការចាក់វ៉ាក់សាំងដដែលនេះជាលើកទី២ (ដូសទី២) ក្នុងរយៈពេលពី ១៤ ទៅ ២៨ថ្ងៃ (មិនឱ្យលើសពី ២៨ថ្ងៃ) បន្ទាប់ពីថ្ងៃចាក់លើកទី១ កុំបីអាក់ខានឡើយ។

សូមបងប្អូនប្រជាពលរដ្ឋ ក្នុងក្រុមអាទិភាពផ្សេងៗទៀត ដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩ មេត្តាអធ្យាស្រ័យប្រសិនបើមិនទាន់ដល់វេនរបស់ខ្លួនទេនោះ សូមមេត្តារង់ចាំបន្តិចសិន ព្រោះវ៉ាក់សាំងមានចំនួនកំណត់ និងមកជាបន្តបន្ទាប់ទៀត។

ថ្ងៃសៅរ៍ ៨រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**

**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**